**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ៣៣៤៨ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពីកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹង ដល់សហគ្រាស អ្នកប្រកបអាជីវកម្ម និងអង្គការនានា អំពីកាតព្វកិច្ចដូចខាងក្រោម÷

- ត្រូវធ្វើការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ
- ត្រូវធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដាររបស់ខ្លួនតាមការជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ចំពោះការចុះបញ្ជីពន្ធដារទាំងអស់ ដែលបានធ្វើមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤។

សហគ្រាស អ្នកប្រកបអាជីវកម្ម និងអង្គការនានា មានកាតព្វកិច្ចចុះបញ្ជីពន្ធដារតាមនីតិវិធីដូចខាងក្រោម÷

**១. ការចុះបញ្ជីតាមរបបពិត (របបស្វ័យប្រកាស)**

ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ ក្នុងការស្នើសុំចុះបញ្ជីពន្ធដារតាមរបបពិត (របបស្វ័យប្រកាស) សហគ្រាសឯកបុគ្គល សហគ្រាសនីតិបុគ្គល និងអង្គការនានា ត្រូវធ្វើការស្នើសុំចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ (អគារសាលាជាតិពន្ធដារ លេខ៤១-៤៣ ផ្លូវលេខ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ) ឬចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដែលមាននៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋាន ពន្ធដារ www.tax.gov.kh។

ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ឬប្រធានអង្គការ ត្រូវមកថតរូប និងស្កែន (Scan) ម្រាមដៃផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ (អគារសាលាជាតិពន្ធដារ) និងត្រូវបំពេញព័ត៌មានក្នុងទម្រង់ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងភ្ជាប់មកជាមួយនូវឯកសារដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

**២. ការចុះបញ្ជីតាមរបបម៉ៅការ**

ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ ក្នុងការស្នើសុំចុះបញ្ជីពន្ធដារតាមរបបម៉ៅការ អ្នកប្រកបអាជីវកម្មទាំងអស់ត្រូវធ្វើការស្នើសុំចុះបញ្ជីនៅសាខាពន្ធដារខេត្ត-ខណ្ឌ ដែលអាជីវកម្មដ្ឋានស្ថិតនៅ ឬចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដែលមាននៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh។

អ្នកប្រកបអាជីវកម្មត្រូវបំពេញព័ត៌មានក្នុងទម្រង់ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងភ្ជាប់ជាមួយនូវឯកសារដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

ដោយឡែក សហគ្រាស អ្នកប្រកបអាជីវកម្ម និងអង្គការនានា ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានតាមការជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដោយអនុវត្តតាមនីតិវិធីដូចការស្នើសុំចុះបញ្ជីពន្ធដារខាងលើ។

ក្នុងករណី មិនបានចុះបញ្ជីពន្ធដារ ឬមិនបានធ្វើបច្ចុប្បន្នភាពព័ត៌មាន សហគ្រាស អ្នកប្រកបអាជីវកម្ម និងអង្គការនានា ត្រូវរងទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងរដ្ឋបាលសារពើពន្ធដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ 023 884 481/023 884 485 ឬអ៊ីម៉ែល: registration@tax.gov.kh ឬចូលទៅគេហទំព័រ www.tax.gov.kh។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថា សហគ្រាស អ្នកប្រកបអាជីវកម្ម និងអង្គការនានា ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

Collection by VCAT Professional Consultant